ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ០៧៧៣/១៥ គជបជ

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពក្រុមការងារការពារជនរងគ្រោះ

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ:០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការ បង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញសេចក្តីសម្រេចរាជរដ្ឋាភិបាល លេខ ១៤៥ សសរ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ
- បានឃើញអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញសេចក្តីសម្រេចលេខ ០៩៤/១៤ សសរ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## សម្រេច

**ប្រការ១**.

ត្រូវបានតែងតាំងសមាសភាព ក្រុមការងារការពារជនរងគ្រោះនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសមាសភាពដូចខាងក្រោម ៖

១. ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ) **ប្រធាន**

២. លោកជំទាវ **ខៀវ បូរី** រដ្ឋលេខាធិការក្រសួង ស.អ.យ អនុប្រធានអចិន្ត្រៃយ៍

៣. ឯកឧត្តម **អ៊ិន វិធុរៈ** អនុរដ្ឋលេខាធិការក្រសួង ស.អ.យ អនុប្រធាន

៤. លោកជំទាវ **ម៉ែន រិតស៊ី** អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល អនុប្រធាន

៥. ល.ជ.ឧត្តមសេនីយ៍ទោ **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការរង គ.ជ.ប.ជ អនុប្រធាន

៦. ឯកឧត្តម **តូច ចាន់នី** អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេសក្រសួងស.អ.យ សមាជិក

៧. ល.ជ.ឧត្តមសេនីយ៍ឯក **ឌុច ដាណា** អគ្គនាយករងនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សមាជិក

៨. លោក **សុច សុផាន់ណារ៉ា** អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ សមាជិក

៩. លោកឧត្តមសេនីយ៍ត្រី **ខែ៉ត សំណាង** នាយករងទីចាត់ការការងារព្រំដែន ក្រសួងការពារជាតិ សមាជិក

១០.លោកស្រី **អ៊ឹង វណ្ណឫទ្ធី** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ក្រសួង ស.អ.យ សមាជិក

១១. លោក **ស៊ីន សេងហុក** ប្រធាននាយកដ្ឋាននីតិកម្ម ក្រសួងអប់រំយុវជន និងកីឡា សមាជិក

១២. លោក **វេង ហៀង** ប្រធាននាយកដ្ឋានការងារកុមារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៣. លោក **ជីន ចន** អនុប្រធាននាយកដ្ឋានការពារផ្លូវច្បាប់ ក្រសួងកិច្ចការនារី សមាជិក

១៤. លោក **គឹម សុវណ្ណា** អនុប្រធាននាយកដ្ឋានច្បាប់-កុងស៊ុល ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៥. លោកស្រី **ខាន់ ច័ន្ទវណ្ណា** អនុប្រធាននាយកដ្ឋាន ក្រសួងព័ត៌មាន សមាជិក

១៦.ល.ស.ឧត្តមសេនីយ៍ត្រី **ណា នាង** អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ សមាជិក

១៧.លោកឧត្តមសេនីយ៍ត្រី **ម៉ុក ប៊ុនឈាង** អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ សមាជិក

១៨. លោកស្រី **កែវ ម៉ាលី** អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងសមាហរណកម្មជនរងគ្រោះ ក្រសួង ស.អ.យ សមាជិក

១៩. លោកវរសេនីយ៍ទោ **សោម វណ្ណេត** នាយរងការិយាល័យស្រាវជ្រាវ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ សមាជិក

២០. លោកវរ.ទោ **ស សាខុធ** នាយរងការិយាល័យបទល្មើសជួញដូរមនុស្ស ស្នងការដ្ឋានយុត្តិធម៌ កងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

២១. លោក **ណុប ឫទ្ធា** ប្រធានផ្នែកការពារកុមារ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សមាជិក

២២. ឯកឧត្តម **នុត សវនា** សមាជិកគណៈកម្មាធិការកណ្តាលសហភាពសហព័ន្ធយុវជន សមាជិក

២៣. លោក **ម៉ម ដារ៉ូ** អនុប្រធានការិយាល័យស្តារនិងទំនាក់ទំនងគ្រួសារនៃនាយកដ្ឋានទំនាក់ទំនង កាកបាទក្រហមកម្ពុជា សមាជិក

| | | | |
|---|---|---|---|
| ២៤. តំណាង | | អង្គការសកម្មភាពសហប្រជាជាតិដើម្បីប្រឆាំងការជួញដូរមនុស្ស | សមាជិក |
| ២៥. លោក | **នុត សំអុល** | ជំនួយការកម្មវិធីអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) | សមាជិក |
| ២៦. កញ្ញា | **យឹម សុតារី** | ជំនួយគម្រោង UNODC | សមាជិក |
| ២៧. លោក | **ឃ្លាំង រឹម** | មន្ត្រីគម្រោងអង្គការពលកម្មអន្តរជាតិ (ILO) | សមាជិក |
| ២៨. លោក | **ហេង សុហ៊ាញ** | នាយកកម្មវិធីបញ្ឈប់ការជួញដូរមនុស្ស អ.កទស្សនៈពិភពលោក | សមាជិក |
| ២៩. លោក | **ថា សារ៉ាវុធ** | មន្ត្រីជំនាញផ្នែកនគរបាលការពារជនរងគ្រោះនៃគម្រោងប្រឆាំងការជួញដូរមនុស្ស អង្គការវីនរ៉ក់ | សមាជិក |
| ៣០. លោកស្រី | **ប៉ុក បញ្ញាវិចិត្រ** | ប្រធានអង្គការ ជួយស្ត្រីមានវិបត្តិ (CWCC) | សមាជិក |
| ៣១. លោក | **ស៊ុន ឋាវិន្ឋ** | ប្រធាន អង្គការសម្ព័ន្ធចាប់ដៃ | សមាជិក |
| ៣២. លោក | **សេក សុផល** | ប្រធានកម្មវិធីមជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ | សមាជិក |
| ៣៣.លោក | **ឆន អាន** | ប្រធានកម្មវិធីសុខភាព សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ | សមាជិក |

**ប្រការ២.**

ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារការពារជនរងគ្រោះ ត្រូវអនុវត្តតាមតួនាទី និងភារកិច្ចដូចមានចែងក្នុងប្រការ៤ នៃសេចក្តីសម្រេចគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លេខ ០៩៤/១៤ សសរ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ស្តីពី ការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យមានប្រសិទ្ធភាព ។ ប្រធានក្រុមការងារ អាចចាត់តាំងមន្ត្រី ជាជំនួយតាមការចាំបាច់ ។

អង្គការដៃគូពាក់ព័ន្ធ ជាតិ និងអន្តរជាតិដែលមានគោលដៅស្របទៅនឹងភារកិច្ចដែលកំណត់ដោយសេចក្តីសម្រេចលេខ ០៩៤/១៤ សសរ ខាងលើនេះ អាចស្នើសុំចូលជាសមាជិកក្រុមការងារ មកប្រធានក្រុមការងារការពារជនរងគ្រោះ និងចាត់តំណាងផ្លូវការមកចូលរួម តាមការអញ្ជើញរបស់ប្រធានក្រុម ។

**ប្រការ៣.**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អង្គការដៃគូពាក់ព័ន្ធ ជាតិ និងអន្តរជាតិ និងសាមីខ្លួនដូចក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.ប.ជ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- អគ្គលេខាធិការ គ.ជ.ប.ជ
- ក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ
- ក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ
- សាមីខ្លួនដូចប្រការ១
- ឯកសារ កាលប្បវត្តិ